# ជំងឺ pneumococcal ក្នុងកុមារភាព

Khmer

គម្រោងពេលនៃកម្មវិធីជាតិសម្រាប់ការចាក់ថ្នាំបង្ការរោគ ផ្តល់ជូនការចាក់ថ្នាំបង្ការជំងឺ pneumococcal ដោយឥតគិតថ្លៃចំពោះទារកទាំងអស់ក្នុងអាយុពីរ បួន និង១២ខែ។ កុមារមានអាយុតិចជាងប្រាំឆ្នាំ ដែលមានស្ថានភាពព្យាបាលរោគសំខាន់ចាំបាច់ ក៏មានសិទ្ធិទទួលបានការចាក់ថ្នាំបង្ការជំងឺ pneumococcal បន្ថែមទៀតដែរ។

## ជំងឺ Pneumococcal

ជំងឺ Pneumococcal ក្នុងកុមារវ័យក្មេង បណ្តាលឲ្យមានរោគធ្ងន់ធ្ងរដូចជាការឆ្លងរោគក្នុងឈាម ហើយរហូតដល់ស្លាប់ទៀតផង។ កុមារដែលមានស្ថានភាពសុខភាពធ្ងន់ធ្ងរ មានគ្រោះថ្នាក់យ៉ាងខ្លាំងដោយរោគឆ្លងដែលគំរាមកំហែងដល់ជីវិត និងការចូលព្យាបាលក្នុងមន្ទីរពេទ្យ។

មនុស្សភាគច្រើនមានផ្ទុកបាក់តេរីនៃរោគ Streptococcus pneumoniae ក្នុងច្រមុះ និងក្នុងបំពង់ក។ បាក់តេរីទាំងនេះឆ្លងរាលដាលដោយតំណក់ទឹកល្អិតៗចេញពីមាត់ និងច្រមុះ ដូចជាការក្អក និងកណ្តាស់ជាដើម ឬដោយការប៉ះពាល់ជាមួយគ្រឿងប្រដាប់ដែលក្រខ្វក់ដោយសារតំណក់ទឹកល្អិតៗចម្លងរោគ។
ជំងឺឆ្លង Pneumococcal វាយប្រហារលើផ្នែកផ្សេងៗនៃរាងកាយ។ ឧទាហរណ៍

- ប្រសិនបើបាក់តេរីបង្កជំងឺ pneumococcal ចូលទៅក្នុងចរន្តឈាម វាត្រូវបានគេហៅថា bacteraemia (វត្តមាននៃបាក់តេរីក្នុងឈាម)
- ប្រសិនបើវាវាយប្រហារផ្នែកជាក់លាក់ណាមួយនៃខួរក្បាល វាត្រូវបានគេស្គាល់ថាជារោគរលាកស្រោមខួរ។
- ប្រសិនបើបាក់តេរីបង្កជំងឺ pneumococcal វាយប្រហារសួត វាត្រូវបានគេស្គាល់ថាជារោគរលាកសួត
- ប្រសិនបើវាឆ្លងទៅផ្នែកកណ្តាលនៃត្រចៀក វាត្រូវបានគេហៅថារោគអំបៅអំបែក ។

## ថ្នាំបង្ការជំងឺ pneumococcal

ការចាក់ថ្នាំបង្ការជំងឺសម្រាប់កុមារ បានបង្ហាញថាមានប្រសិទ្ធិភាពស្ទើរតែ១០០ភាគរយប្រឆាំងនឹងប្រភេទនៃជំងឺ pneumococcal ដ៏ធ្ងន់ធ្ងរ។ ទោះជាយ៉ាងនេះក្តី មានអម្បូរបាក់តេរីជំងឺ pneumococcal ច្រើនជាង៩០។ ថ្នាំចាក់បង្ការជំងឺ pneumococcal មួយ គ្របដណ្តប់លើអម្បូរដែលបណ្តាលឲ្យមានពី៨០ភាគរយ ទៅ៩០ភាគរយនៃករណីនៃជំងឺ pneumococcal ដ៏ធ្ងន់ធ្ងរ។ ថ្នាំចាក់បង្ការជំងឺ pneumococcal ដទៃមួយទៀតដែលសមរម្យសម្រាប់កុមារអាយុច្រើនជាង ក៏ត្រូវបានចាក់ឲ្យដែរ ប្រសិនបើកុមារមានស្ថានភាពរោគសំខាន់ចាំបាច់ ដោយព្រោះថាវាមានអម្បូរច្រើន ដើម្បីការពារទប់ទល់នឹងជំងឺឆ្លង pneumococcal។ ថ្នាំចាក់បង្ការជំងឺមានសមាសភាគអសកម្មនៃអម្បូរបាក់តេរីជំងឺ pneumococcal មួយចំនួន សម្រាប់ជំរុញឲ្យមានការឆ្លើយតបនៃភាពស៊ាំនឹងរោគ។

## តើនរណាមានសិទ្ធិទទួលការចាក់ថ្នាំបង្ការជំងឺ pneumococcal ដោយឥតគិតថ្លៃ?

- ទារកទាំងអស់ក្នុងអាយុ២ខែ ៤ខែ និង១២ខែ។
- កុមារអាយុរហូតដល់ប្រាំឆ្នាំដែលមានកត្តាគ្រោះថ្នាក់រោគដែលដាក់ឲ្យគេប្រឈមមុខនឹងគ្រោះថ្នាក់កំរិតខ្ពស់នៃការឆ្លងជំងឺ pneumococcal។ កុមារទាំងនេះត្រូវការការចាក់ថ្នាំបង្ការជំងឺ pneumococcal បន្ថែមនៅអាយុប្រាំមួយខែ និងនៅអាយុបួនទៅប្រាំឆ្នាំ។

សូមនិយាយជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ដើម្បីពិភាក្សាអំពីស្ថានភាពរោគសំខាន់ចាំបាច់ទាំងឡាយដូចជា:

- រោគឆ្លង HIV
- រោគមហារីកឈាម
- រោគធ្វើឲ្យស្វះស្វូត និងប្រព័ន្ធរំលាយអាហារដោយសារស្លេះស្អិត
- រោគធ្លាយវត្ថុរាវពីភ្នាសស្រោបខួរក្បាល និងពីប្រព័ន្ធសរសៃប្រសាទឆ្អឹងខ្នង
- រោគហើមប៉ោងលលាដ៏ក្បាល
- ការផ្សាំគ្រឿងសិប្បនិមិត្តក្នុងត្រចៀកដើម្បីឲ្យស្តាប់ឮ
- ប្រព័ន្ធការពាររោគអន់ថយដោយសារជំងឺ ការប្រើថ្នាំពេទ្យ ឬការព្យាបាលរោគ
- ការបំពេញមុខងាររបស់អណ្តើកចុះអន់ថយ ឬគ្មានអណ្តើក
- រោគ Down syndrome
- ទារកទាំងអស់ដែលកើតក្នុងអំឡុងពេលតិចជាង២៨សប្តាហ៍នៃការមានផ្ទៃពោះ
- ជំងឺរ៉ាំរ៉ៃបេះដូង សួត ក្រលៀន និងជំងឺទឹកនោមផ្អែម។

## ផលវិបាករាយរងដែលអាចកើតមានពីការចាក់ថ្នាំបង្ការជំងឺ pneumococcal

### ផលវិបាករាយរងទូទៅ

- ឈឺចាប់ ឡើងក្រហម ឬហើមនៅត្រង់កន្លែងចាក់ថ្នាំ
- សីតុណ្ហភាពកំរិតទាប។

### ផលវិបាករាយរងដែលកម្រនឹងកើតមានណាស់

- ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ

ប្រសិនបើកើតមានប្រតិកម្មមិនធ្ងន់ធ្ងរ ផលវិបាករាយរងអាចកាត់បន្ថយបានដោយ:

- ដាក់ក្រណាត់ទទឹកត្រជាក់លើកន្លែងចាក់ថ្នាំ
- កុំស្លៀកពាក់ឲ្យកូនលោកអ្នកច្រើនហួស
- អាចត្រូវការប្រើថ្នាំ paracetamol ដើម្បីធ្វើឲ្យធូរស្រាលភាពពុំសុខស្រួល និង/ឬគ្រុនក្តៅខ្លាំង (សូមផែកមើលស្លាកព័ត៌មានដើម្បីប្រើប្រាស់ឲ្យបានត្រឹមត្រូវ )
- ឲ្យទឹករបស់កូនលោកអ្នកផឹកច្រើនថែមទៀត

ប្រសិនបើប្រតិកម្មមានសភាពធ្ងន់ធ្ងរ ឬពុំធូរស្រាល ឬប្រសិនបើលោកអ្នកព្រួយបារម្ភអំពីកូនរបស់លោកអ្នក សូមទាក់ទងជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ឬមន្ទីរពេទ្យ។

## បញ្ជីផែកមើលមុនការចាក់ថ្នាំបង្ការរោគ

មុនលោកអ្នកឲ្យកូនរបស់លោកអ្នកចាក់ថ្នាំបង្ការរោគ សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក ប្រសិនបើកូនរបស់លោកអ្នកៈ

- ☐ មិនស្រួលខ្លួននៅថ្ងៃចាក់ថ្នាំបង្ការរោគ
- ☐ ធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរទៅនឹងថ្នាំចាក់បង្ការរោគណាមួយ
- ☐ មានការទាស់ទៅនឹងសមាសភាគណាមួយនៃថ្នាំ

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមស្វែងរក 'ការចាក់ថ្នាំបង្ការរោគកុមារភាព' នៅត្រង់វិបសាយ http://www.betterhealth.vic.gov.au

សម្រាប់កំណែបកប្រែនៃឯកសារនេះ សូមចូលទៅកាន់វិបសាយ http://www.healthtranslations.vic.gov.au

សម្រាប់ព័ត៌មានអំពីកម្មវិធីជាតិលើការចាក់ថ្នាំបង្ការរោគ សូមបើកចូលវិបសាយ http://www.immunise.health.gov.au/

© រក្សាសិទ្ធិ ក្រសួងសុខាភិបាល ឆ្នាំ២០១០។
អនុញ្ញាតដោយរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា 50 Lonsdale St, Melbourne.
ខែមករា ឆ្នាំ២០១១។ PH616 (1011012 )

Interpreter

**Translating and interpreting service**
**Call 131 450**